# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៣០-សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលប្រការ ១ នៃសេចក្តីសម្រេចលេខ ៣៥ សសរ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីអប់រំ និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញសេចក្តីសម្រេចលេខ ៣៥ សសរ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីអប់រំ និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

## ស ម្រេ ច

**ប្រការ មួយ.-**

ត្រូវបានកែសម្រួលប្រការ ១ នៃសេចក្តីសម្រេចលេខ ៣៥ សសរ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីអប់រំ និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់ ។

www.pheakdeylaw.com

**ប្រការ ១ ថ្មី.-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងដែលមានឈ្មោះ " គណៈកម្មការអន្តរក្រសួងដើម្បីអប់រំ និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់ " ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១. រដ្ឋមន្ត្រីក្រសួងសុខាភិបាល | ប្រធាន |
| ២. រដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | អនុប្រធាន |
| ៤. អនុរដ្ឋលេខាធិការ ឬតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១រូប សមាជិក |
| ៥. អនុរដ្ឋលេខាធិការ ឬតំណាងក្រសួងពាណិជ្ជកម្ម | ០១រូប សមាជិក |
| ៦. អនុរដ្ឋលេខាធិការ ឬតំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ០១រូប សមាជិក |
| ៧. អនុរដ្ឋលេខាធិការ ឬតំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ០១រូប សមាជិក |
| ៨. អនុរដ្ឋលេខាធិការ ឬតំណាងក្រសួងបរិស្ថាន | ០១រូប សមាជិក |
| ៩. អនុរដ្ឋលេខាធិការ ឬតំណាងក្រសួងកិច្ចការនារី | ០១រូប សមាជិក |
| ១០. អនុរដ្ឋលេខាធិការ ឬតំណាងក្រសួងអប់រំយុវជន និងកីឡា | ០១រូប សមាជិក |
| ១១. អនុរដ្ឋលេខាធិការ ឬតំណាងក្រសួងធម្មការ និងសាសនា | ០១រូប សមាជិក |
| ១២. អគ្គលេខាធិការរងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន | ០១រូប សមាជិក |
| ១៣. នាយកខុទ្ទកាល័យក្រសួងមហាផ្ទៃ | ០១រូប សមាជិក |
| ១៤. ប្រធានមជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព | សមាជិក និងជាលេខាធិការ |

**ប្រការ ពីរ.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ បី.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល :***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

www.pheakdeylaw.com